# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ ០០៣៤/...... ន.គ.ស/សរ.ស.ណ./២៤

ថ្ងៃអង្គារ ១៣កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ, ថ្ងៃទី ៤ ខែមិថុនា ឆ្នាំ២០២៤

# សេចក្តីជូនដំណឹង

## ស្តីពី

## ការសម្រេចរបស់រាជរដ្ឋាភិបាល សម្រាប់គ្រឹះស្ថានសិក្សារដ្ឋនិងឯកជន ក្នុងការអនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្ម

**និយ័តករគណនេយ្យនិងសវនកម្ម** (ន.គ.ស.) នៃ **អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** (អ.ស.ហ.) មានកិត្តិយសសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា** ជាគណៈគ្រប់គ្រង **គ្រឹះស្ថានសិក្សារដ្ឋនិងឯកជន** ជ្រាបថា÷ យោងលិខិតលេខ ៧១៦ សជណ.អវ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចឯកភាពបន្តពន្យារការអនុវត្តនូវប្រាក់ពិន័យអន្តរការណ៍ជូនគ្រឹះស្ថានសិក្សារដ្ឋនិងឯកជន រហូតដល់ដំណាច់ ឆ្នាំ២០២៨ ប៉ុន្តែដើម្បីពង្រឹងអនុលោមភាព គ្រឹះស្ថានសិក្សារដ្ឋនិងឯកជន ត្រូវអនុវត្តនូវលក្ខខណ្ឌមួយចំនួន គ្រឹះស្ថានសិក្សារដ្ឋនិងឯកជន ត្រូវ÷

១. អនុវត្តកាតព្វកិច្ចកាន់បញ្ជីគណនេយ្យឱ្យបានត្រឹមត្រូវ

២. រៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ

៣. ដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ មក **ន.គ.ស.**។

លើសពីនេះទៅទៀត គ្រឹះស្ថានសិក្សា គួរមានឆន្ទៈរៀបចំផែនការច្បាស់លាស់ក្នុងការចូលរួមសិក្សាស្រាវជ្រាវ និងចូលរួមការបណ្តុះបណ្តាលស្តង់ដាគណនេយ្យ ដែលរៀបចំដោយ **ន.គ.ស.** និងគ្រឹះស្ថានបណ្តុះបណ្តាលផ្សេងទៀត។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា** ជាគណៈគ្រប់គ្រង **គ្រឹះស្ថានសិក្សារដ្ឋនិងឯកជន** ជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តខ្លឹមសារនៃសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

**និយ័តករគណនេយ្យនិងសវនកម្ម**

ដើម្បីទទួលបានបច្ចុប្បន្នភាពព័ត៌មានអំពីវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម
សូមចូលរួមក្នុង Telegram Channel
របស់និយ័តករគណនេយ្យនិងសវនកម្ម

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**លេខ:** ៣១៦ សជណ.អវ

ថ្ងៃ សុក្រ ៤រោច ខែ ពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**សូមគោរពជូន**

- **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
- **ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
- **ឯកឧត្តមសាស្ត្រាចារ្យ រដ្ឋមន្ត្រីក្រសួងសុខាភិបាល**
- **ឯកឧត្តមបណ្ឌិត ប្រធានក្រុមប្រឹក្សាភិបាលនៃសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា**

**កម្មវត្ថុ៖** ករណីលទ្ធផលនៃជំនួបរវាងសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាមួយប្រតិភូនៃសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា កាលពីថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៤ នៅវិមានសន្តិភាព។

**យោង** ៖- លិខិតលេខ២៥២ សជណ.អវ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ០៩៥ ខន/០២៤ សជណ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៤ របស់ខុទ្ទកាល័យសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ប្រសាសន៍ដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៤។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តម ជ្រាបថា រាជរដ្ឋាភិបាលសម្រេច ដូចខាងក្រោម៖

១-ឯកភាពបន្តផ្តល់ការអនុគ្រោះ សម្រួលដល់គ្រឹះស្ថានសិក្សារដ្ឋ និងឯកជន ឱ្យរួចផុតពីការបង់ពន្ធលើប្រាក់ចំណូល ប្រាក់រំដោះពន្ធលើប្រាក់ចំណូល ពន្ធអប្បបរមា អាករលើតម្លៃបន្ថែម និងពន្ធកាត់ទុកលើសេវាការប្រាក់ និងភាគលាភ ចាប់ពីឆ្នាំ២០២៤ រហូតដល់ដំណាច់ឆ្នាំ២០២៨ ដោយអនុវត្តតាមខ្លឹមសារនៃលិខិតលេខ២៥២ សជណ.អវ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ទីស្តីការគណៈរដ្ឋមន្ត្រី និងប្រកាសថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ ស្តីពីការលើកទឹកចិត្តពន្ធដារចំពោះវិស័យអប់រំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

២-ឯកភាពបន្តពន្យារការអនុវត្តនូវប្រាក់ពិន័យអន្តរការណ៍របស់និយ័តករគណនេយ្យនិងសវនកម្ម រហូតដល់ដំណាច់ឆ្នាំ២០២៨ ប៉ុន្តែគ្រឹះស្ថានសិក្សារដ្ឋនិងឯកជន ត្រូវអនុវត្តនូវលក្ខខណ្ឌមួយចំនួន ដោយគ្រឹះស្ថានសិក្សារដ្ឋ និងឯកជន ត្រូវអនុវត្តកាតព្វកិច្ចកាន់បញ្ជីគណនេយ្យត្រឹមត្រូវ រៀបចំរបាយការណ៍ហិរញ្ញវត្ថុនិងដាក់បញ្ចូលរបាយការណ៍ហិរញ្ញវត្ថុមកនិយ័តករគណនេយ្យនិងសវនកម្ម ហើយគ្រឹះស្ថានសិក្សារដ្ឋ និងឯកជន គួរមានឆន្ទៈរៀបចំផែនការច្បាស់លាស់ក្នុងការចូលរួមសិក្សាស្រាវជ្រាវ និងចូលរួមការបណ្តុះបណ្តាលស្តង់ដាគណនេយ្យ ដែលរៀបចំដោយនិយ័តករគណនេយ្យនិងសវនកម្ម និងគ្រឹះស្ថានបណ្តុះបណ្តាលផ្សេងៗទៀត ខិតខំជំរុញបន្ថែមនូវសកម្មភាពផ្សព្វផ្សាយនិងបណ្តុះបណ្តាល ស្របតាមវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ដែលមានស្រាប់។

៣-ឯកភាពផ្តល់នូវសាល ក្នុងអគារជាន់ទី១ នៃអគារបណ្ណាល័យសម្តេចអគ្គមហាសេនាបតីតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិតបច្ចុប្បន្ន សម្រាប់សមាគមប្រើប្រាស់ក្នុងដំណើរការការងារប្រចាំថ្ងៃរបស់ខ្លួន។

ជាមួយគ្នានេះ រាជរដ្ឋាភិបាលក៏បានជំរុញដល់សមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា យកចិត្តទុកដាក់លើកិច្ចការសំខាន់៣ ដូចខាងក្រោម៖

១-ពិនិត្យលទ្ធភាពសហការជាមួយនឹងក្រសួង ស្ថាប័ន ដើម្បីបណ្តុះបណ្តាលជំនាញដែលឆ្លើយតបទៅនឹងតម្រូវការរបស់ក្រសួង-ស្ថាប័ន និងសហការជាមួយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារនៅកម្ពុជា។

២-ត្រូវរួមគិត រួមធ្វើ និងរួមទទួលខុសត្រូវ តាមរយៈការចូលរួមអនុវត្តនូវយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន ដើម្បីពង្រឹងនិងពង្រីកការអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា ព្រមទាំងការដាក់ចេញនូវយន្តការនៅក្នុងការត្រួតពិនិត្យតាមដាន ដើម្បីតម្រង់ទិសទៅតាមវិស័យនីមួយៗ។

៣-បញ្ចូលក្នុងកម្មវិធីសិក្សានូវភាសាខ្មែរ សិល្បៈ វប្បធម៌ សីលធម៌ គុណធម៌ និងប្រវត្តិសាស្ត្រ ព្រោះថាទោះបីជាប្រទេសជាតិមានការអភិវឌ្ឍទៅដល់ណាក៏ដោយ ក៏ត្រូវតែរក្សាបាននូវអត្តសញ្ញាណជាតិផងដែរ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម ជ្រាបនិងចាត់ចែងអនុវត្ត។

ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
រដ្ឋលេខាធិការ

អ៊ីន ទីរជាតិ

**ចម្លងជូន៖**
-គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
-ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
-អគ្គនាយកដ្ឋានពន្ធដារ
-និយ័តករគណនេយ្យនិងសវនកម្ម
-សហព័ន្ធសេវាអប់រំនៅកម្ពុជា
-ឯកសារ កាលប្បវត្តិ